# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រាតែមួយ ..**

កែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន មានដូចខាងក្រោម :

**មាត្រា៥៩ថ្មីស្ទួន ..**

ក. ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួល អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយប្តីប្រពន្ធ សុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**ខ.**ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦ ប្រជាពលរដ្ឋខ្មែរដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋាន រួមមាន បញ្ជាក់កំណើត និង បញ្ជាក់ មរណភាព នឹងត្រូវផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥត គិតថ្លៃ ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៦ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែល ឪពុក ឬ ម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេល មិនហួសពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើត ច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី ហ.ស.ត.

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង នរោត្តម សិរីវុឌ្ឍ**